ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# ប្រកាស

# ស្តីពី

# នីតិវិធីអនុវត្តគោលនយោបាយ

# ស្តីពីការថែទាំជំនួសចំពោះកុមារ




តុលា ២០១១

ឧបត្ថម្ភការថតចម្លងដោយកម្មវិធីបញ្ឈប់ការជួញដូរមនុស្សនៃអង្គការទស្សនៈពិភពលោកអន្តរជាតិ

World Vision

# បុព្វកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិមានការអភិវឌ្ឍលើគ្រប់វិស័យ និងសម្រេចបាននូវសមិទ្ធិផលធំៗជាច្រើន ។ ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០០៩-២០១៣ ទទួលបានជោគជ័យជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវយុទ្ធសាស្ត្រគាំពារសង្គមជាតិសម្រាប់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ សំដៅបង្កើនល្បឿននៃការអភិវឌ្ឍឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍសហសវត្ស។ ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រនេះ បានផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់កិច្ចការពារគ្រួសារ និងកុមារងាយរងគ្រោះ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារនៅឆ្នាំ២០០៦ ដែលមានគោលបំណង "ធានាថា កុមារធំលូតលាស់នៅក្នុងគ្រួសារ និងសហគមន៍" និងលើកស្ទួយទស្សនទានថា "ការថែទាំកុមារនៅតាមមណ្ឌលគឺជាជម្រើសចុងក្រោយនិងជាដំណោះស្រាយបណ្តោះអាសន្ន"។ តាមរយៈគោលនយោបាយនេះ ក្រសួងក៏បានលើកទឹកចិត្តដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតឲ្យចូលរួមអនុវត្តគោលនយោបាយ និងកម្មវិធីនានាទាក់ទងនឹងការថែទាំជំនួស កសាងសមត្ថភាពមន្ត្រីដែលធ្វើការជាមួយកុមារបង្កើតនូវប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

ក្រសួងបានចេញប្រកាសលេខ ៦១៦ សអយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងប្រកាសលេខ ១៩៨ សអយ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍។ បទដ្ឋានអប្បបរមាទាំងនេះចែងលម្អិតនូវលក្ខខណ្ឌ និងបទដ្ឋានជាមូលដ្ឋានសម្រាប់ពង្រឹងការងារគ្រប់គ្រងមណ្ឌលថែទាំកុមារ កម្មវិធីថែទាំជំនួសនៅតាមសហគមន៍ និងការរៀបចំចាត់ចែងទុកដាក់កុមារនៅតាមសហគមន៍ និងតម្រូវអោយមានការទទួលខុសត្រូវរបស់អ្នកថែទាំកុមារ ព្រមទាំងនីតិវិធីបណ្តឹង និងកិច្ចការពារផ្លូវច្បាប់ ក្នុងករណីមានការរំលោភបំពាន។ បទដ្ឋានទាំងនេះក៏បង្កើតនូវយន្តការត្រួតពិនិត្យតាមដាន និងការដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តិល្មើស។ ផ្អែកតាមគោលនយោបាយ និងបទបញ្ញាទាំងនេះ ក្រសួងបានត្រួតពិនិត្យតាមដានយ៉ាងសកម្មលើមណ្ឌល និងកម្មវិធីថែទាំជំនួសចំពោះកុមារ និងបានផ្តល់អនុសាសន៍ឲ្យកែលម្អជាបន្តបន្ទាប់។

ដើម្បីបង្កើតឲ្យបានប្រព័ន្ធដែលអាចទប់ស្កាត់ និងការពារកុមារឲ្យរួចផុតពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងអំពើហិង្សា ព្រមទាំងឆ្លើយតបនឹងភាពងាយរងគ្រោះនានា ជាការចាំបាច់ត្រូវការពេលវេលា និងកិច្ចខិតខំប្រឹងប្រែងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

ឆ្នាំ២០០៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំប្រកាសស្តីពីនីតិវិធីសម្រាប់អនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ដើម្បីផ្តល់ជាការណែនាំយ៉ាងលម្អិតពីការកំណត់អត្តសញ្ញាណកុមារងាយរងគ្រោះ កុមារប្រឈមនឹងគ្រោះថ្នាក់នៃការបែកចេញពីគ្រួសារ កុមារស្ថិតក្នុងភាពងាយរងគ្រោះផ្សេងទៀត ដើម្បីបញ្ជូនកុមារទាំងនោះទៅទទួលសេវាដែល

8H8_2280-PRA-CHI
library.ncdd.gov.kh
015463

ពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិនិងសហគមន៍ ការប៉ាន់ប្រមាណស្ថានភាពកុមារ និងគ្រួសារ ដើម្បីរក្សាកុមារក្នុងគ្រួសារ និងបង្រួបបង្រួមគ្រួសារ ការផ្តល់សេវាថែទាំជំនួសសមស្រប ដែលជាដំណោះស្រាយបណ្តោះអាសន្ននិងការធ្វើផែនការ អចិន្ត្រៃយ៍រួមមាន សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស និងការតាមដានករណី។ ប្រកាសនេះបានកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់មន្ទីរ និងទីភ្នាក់ងារផ្សេងៗគ្នានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឆ្នាំ២០១០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងក្រសួងធម្មការ និងសាសនាយកសេចក្តីព្រាងប្រកាសនេះអនុវត្តសាកល្បងនៅក្នុងឃុំសង្កាត់មួយចំនួនដែលបានជ្រើសរើស ហើយការកែលម្អប្រកាសនេះតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងក្រសួង និងស្ថាបន័ពាក់ព័ន្ធផ្សេងទៀតជឿជាក់ថា ការអនុវត្តន៍ប្រកាសនេះ អាចពង្រឹងបន្ថែមទៀតលើសមត្ថភាពក្នុងការកសាងប្រព័ន្ធសុខុមាលភាពកុមារ ឲ្យសម្រេចបាននូវទិសដៅរួមក្នុងការផ្តល់ការថែទាំ និងកិច្ចការពារដល់កុមាររងគ្រោះ និងអនុវត្តការងារដើម្បីឧត្តមប្រយោជន៍របស់កុមារ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណចំពោះក្រសួងពាក់ព័ន្ធនានា ជាពិសេសក្រសួងមហាផ្ទៃ និងក្រសួងធម្មការ និងសាសនា ស្ថាប័ននានា និងអង្គការមិនមែនរដ្ឋាភិបាល ដែលជានិច្ចកាលបានសហការយ៉ាងល្អជាមួយក្រសួង ក្នុងការការពារ និងលើកស្ទួយសិទ្ធិកុមារ។ ក្រសួងសូមថ្លែងអំណរគុណជាពិសេសចំពោះអង្គការយូនីសេហ្វ ដែលបានផ្តល់ការគាំទ្រទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ក្នុងការរៀបចំ ការសាកល្បង និងការបោះពុម្ព ប្រកាសនេះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមស្វាគមន៍ចំពោះមតិស្ថាបនាលើប្រកាសនេះ ដើម្បីកែលំអ និងការអនុវត្តន៍ឲ្យមានប្រសិទ្ធភាពនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១១

រដ្ឋមន្ត្រី

អ៊ិត សំហេង

# សេចក្តីថ្លែងអំណរគុណ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណចំពោះជូនចំពោះក្រុមការងារបច្ចេកទេស អង្គការយូនីសេហ្វ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ក្នុងខេត្តព្រៃវែង ស្វាយរៀង កំពង់ស្ពឺ កំពង់ធំ ខេត្តបាត់ដំបង ក្រុមការងារថ្នាក់ខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ការិយាល័យ រដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត មន្ទីរធម្មការ និងសាសនា ក្រុមប្រឹក្សាឃុំសង្កាត់ទាំង ២៤ ព្រះសង្ឃ ដូនជី ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលរួមក្នុងការតាក់តែង និងការអនុវត្តសាកល្បងប្រកាសនេះ ។

សូមថ្លែងអំណរគុណជាពិសេសជូនចំពោះក្រុមការងារបច្ចេកទេស ដែលមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **នឹម ធូត** | រដ្ឋលេខាធិការ ក្រសួង ស.អ.យ | ប្រធាន |
| ២- | លោកជំទាវ | **ចំរួ ចាវ៉ាន់ចន្ធី** | អនុរដ្ឋលេខាធិការ ក្រសួង ស.អ.យ | អនុប្រធាន |
| ៣- | ឯកឧត្តម | **ក្រាក់ ចាន់ទឿន** | អគ្គនាយកបច្ចេកទេស ក្រសួង ស.អ.យ | អនុប្រធាន |
| ៤- | លោក | **អ៊ុំ សុផាន់ណារ៉ា** | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | អនុប្រធាន |
| ៥- | លោក | **ទោល យុទ្ធលី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | អនុប្រធាន |
| ៦- | ឯកឧត្តម | **មិញ ចាន់ឡូន** | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៧- | ឯកឧត្តម | **ជា ជាតិ** | ប្រធានមន្ទីរ ស.អ.យ ខេត្តកំពង់ធំ | សមាជិក |
| ៨- | លោក | **គីម ឡៀង** | ប្រធានមន្ទីរ ស.អ.យ ខេត្តបាត់ដំបង | សមាជិក |
| ៩- | លោក | **ចាំ សារ៉ែន** | ប្រធានមន្ទីរ ស.អ.យ ខេត្តស្វាយរៀង | សមាជិក |
| ១០- | លោក | **ថន ចាំ** | ប្រធានមន្ទីរ ស.អ.យ ខេត្តព្រៃវែង | សមាជិក |
| ១១- | លោក | **ឈុយ ឡុំ** | ប្រធានមន្ទីរ ស.អ.យ ខេត្តកំពង់ស្ពឺ | សមាជិក |
| ១២- | លោក | **នូច សុខមុត** | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១៣- | លោក | **សុត ចាន់ចន្ទ្រៈ** | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១៤- | លោកស្រី | **ម៉ូ ស៊ីថា** | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១៥- | លោក | **ទើត ទើម** | អនុប្រធាននាយកដ្ឋាន នៃក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៦- | លោក | **គយ ម៉ួយ** | អនុប្រធាន ការិយាល័យហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ | សមាជិក |

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

# មាតិកា

ទំព័រ


បុព្វកថា ..........២-៣

សេក្តីថ្លែងអំណរគុណ..........៤

មាតិកា នៃប្រកាស ស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ..........៥-៦

ប្រកាស ស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ..........៧

**ជំពូក ទី ១: បទប្បញ្ញត្តិទូទៅ..........៨-១០**

ប្រការ១.គោលដៅ និងទស្សនៈវិស័យរបស់ប្រកាស..........៨

ប្រការ ២. គោលបំណងរបស់ប្រកាស..........៨

ប្រការ ៣. តួនាទី ក្រុមប្រឹក្សាទាក់ទង ទៅ និង ការ អនុវត្តប្រកាស..........៨-៩

ប្រការ ៤. និយមន័យវាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ..........៩-១០

**ជំពូក ទី ២: ស្ថានភាពប្រឈមគ្រោះថ្នាក់ និងតម្រូវការសម្រាប់កិច្ចអន្តរាគមន៍..........១០**

ប្រការ ៥. ស្ថានភាពលំបាកដែលអាចធ្វើឱ្យកុមារប្រឈមគ្រោះថ្នាក់ ..........១០-១១

ប្រការ ៦. កិច្ចការរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ និង កិច្ចសហប្រតិបត្តិការ..........១១

**ជំពូក ទី ៣: តួនាទី និងភារកិច្ចរបស់អង្គភាពពាក់ព័ន្ធ..........១១-១៧**

ប្រការ ៧. តួនាទី និងភារកិច្ចរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយ និង គណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និង កុមារ..........១១-១២

ប្រការ ៨. តួនាទី និងភារកិច្ចរបស់ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ..........១២-១៣

ប្រការ ៩. តួនាទី និងភារកិច្ច របស់ ក្រុមប្រឹក្សាស្រុក ខណ្ឌ និង គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ......១៣-១៤

ប្រការ ១០. តួនាទី និងភារកិច្ចរបស់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា..........១៤-១៥

ប្រការ ១១. តួនាទី និងភារកិច្ចរបស់ ក្រុមប្រឹក្សាខេត្តក្រុង ជាមួយ និង គណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និង កុមារ..........១៥-១៦

ប្រការ ១២. តួនាទី និងភារកិច្ចរបស់ នាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា..........១៦-១៧

**ជំពូកទី ៤: ការផ្តល់សេវាថែរក្សាគ្រួសារ..........១៧-១៩**

ប្រការ ១៣. មតិយោបល់ នៃ ការ ថែរក្សាគ្រួសារ..........១៧

ប្រការ ១៤. នីតិវិធី នៃការ ទទួលបន្ទុក របស់គណៈកម្មាធិការ កិច្ចការនារី ..........១៧-១៨

ប្រការ ១៥. នីតិវិធី នៃការថែរក្សាគ្រួសារ..........១៨

ប្រការ ១៦.កិច្ចការពារសុវត្ថិភាពកុមារ............................................................................................១៨-១៩

**ជំពូកទី ៥: ការផ្តល់សេវាបង្រួបបង្រួមគ្រួសារ.......................................................................១៩-២៤**

ប្រការ ១៧. មតិយោបល់ ក្នុងការ  បង្រួបបង្រួមគ្រួសារ......................................................................១៩

ប្រការ ១៨. និតិវិធីនៃការ បង្រួបបង្រួមគ្រួសារ..................................................................................១៩-២០

ប្រការ ១៩. និតិវិធីសម្រាប់កុមារដែលត្រូវបោះបង់ចោល...................................................................២០-២២

ប្រការ ២០. និតិវិធីស្វែងរកឪពុកម្តាយ ឬ អាណាព្យាបាលរបស់កុមារដែលត្រូវបានគេបោះបង់ចោល.....................២២-២៤

**ជំពូកទី ៦: ការថែទាំជំនួសចំពោះកុមារ....................................................................................២៤-២៦**

ប្រការ ២១.និតិវិធីនៃការការថែទាំជំនួស.........................................................................................២៤

ប្រការ ២២. តួនាទី និងភារកិច្ច ក្នុងការទុកដាក់កុមារ.........................................................................២៤-២៥

ប្រការ ២៣.ការសម្រេចក្នុងការទុកដាក់កុមារ និងការតាមដានត្រួតពិនិត្យ..................................................២៥-២៦

**ជំពូកទី ៧: ការធ្វើផែនការអចិន្ត្រៃយ៍........................................................................................២៦-៣០**

ប្រការ ២៤.ផែនការ នៃការទុកដាក់កុមារអចិន្ត្រៃយ៍...........................................................................២៦-២៧

ប្រការ ២៥. និតិវិធី នៃការស្វែងរកគ្រួសារ និង ទុកដាក់ កុមារអចិន្ត្រៃយ៍..................................................២៧-២៨

ប្រការ ២៦.ការលើកកំពស់ នៃការទុកដាក់កុមារ ក្នុងប្រទេស....................................................................២៨

ប្រការ ២៧. និតិវិធីក្នុងការពង្រឹងថែរក្សាកុមារជាអចិន្ត្រៃយ៍...................................................................២៨

ប្រការ ២៨. និតិវិធីក្នុងការសុំកូនក្នុងប្រទេស......................................................................................២៩-៣០

ប្រការ ២៩. និតិវិធី ការថែរក្សាកុមារជាអចិន្ត្រៃយពីគ្រួសារមួយដែលមិនមែនជាញាតិ......................................៣០

ប្រការ ៣០. ការលើកកំពស់ និង ការថែទាំកុមារដែលមានអាយុលើ ១៥ ឆ្នាំ ...............................................៣០

**ជំពូកទី ៨: អវសានប្បញ្ញត្តិ.......................................................................................................៣០-៣១**

ប្រការ ៣១. ការអនុវត្តប្រកាស.............................................. ..............................................................៣០

ប្រការ៣៣.បទប្បញ្ញត្តិផ្ទុយ......................................................................................................................៣១

ប្រការ ៣៣. ភារកិច្ចអនុវត្ត.....................................................................................................................៣់១

ប្រការ ៣៤. ប្រសិទ្ធភាព និង កាលបរិច្ឆេទ នៃការចុះហត្ថលេខា .......................................................................៣១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៧២៧៨ ស អ យ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១

# ប្រកាស
# ស្តីពី
# នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/១១៤៨ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ៦១៦ ស.អ.យ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល

- បានឃើញប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍
- បានឃើញសេចក្តីណែនាំលេខ ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និង ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ទូទាំងប្រទេស
- យោងតាមការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ជាពិសេសគឺកុមារដែលត្រូវការកិច្ចការពារពិសេស ឬកុមារកំពុងប្រឈមនឹងគ្រោះថ្នាក់ ដើម្បីឱ្យកុមារមានការអភិវឌ្ឍពេញលេញក្នុងបរិយាកាសគ្រួសារប្រកបដោយសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។

**ប្រការ ២.-**

ប្រកាសនេះមានបំណងកំណត់នូវគោលការណ៍ប្រតិបត្តិ នីតិវិធី ទម្រង់នានា និងតួនាទី ភារកិច្ចរបស់អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តទាំងស្រុងនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ សំដៅលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារ ដោយទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការអភិវឌ្ឍនៅក្នុងគ្រួសារអចិន្ត្រៃយ៍ ពិសេសគឺគ្រួសារបង្កើត និងគ្រួសារដែលរស់នៅក្នុងសហគមន៍។

**ប្រការ ៣.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើប្រតិភូកម្មជូនក្រុមប្រឹក្សារាជធានីខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ នូវភារកិច្ចក្នុងវិស័យថែទាំជំនួសចំពោះកុមារ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់ណា ត្រូវជួយដល់ក្រុមប្រឹក្សានៅថ្នាក់នោះ ក្នុងការអនុវត្តភារកិច្ចដែលមានចែងក្នុងប្រកាសនេះ។

ក្រុមប្រឹក្សារាជធានីខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការអនុវត្តតាមគោលការណ៍ណែនាំដូចមានចែងក្នុងប្រកាសនេះ ។

**ប្រការ ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ :

**១- កុមារ** សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។

**២- កុមារកំព្រា** សំដៅដល់កុមារដែលមានឪពុក ម្តាយម្នាក់បានទទួលមរណភាព ឬទាំងពីរនាក់បានទទួលមរណភាព ។

**៣- កុមារងាយរងគ្រោះ** សំដៅដល់កុមារដែលត្រូវការជំនួយដោយសារមានស្ថានភាពលំបាក ឬមានបញ្ហាប្រឈមនានា រាប់បញ្ចូលទាំងកុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ផងដែរ ។

**៤- កុមារដែលត្រូវបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬសាធារណៈជនបានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និងជាកុមារដែលគេមិនស្គាល់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាល ឬជាកុមារដែលឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលបានបោះបង់ចោល និងរកមិនឃើញអ្នកទាំងនោះ ក្នុងរយៈពេលយ៉ាងតិច ៥ ( ប្រាំ) ខែ ជាប់គ្នា ។

**៥- កុមារដែលត្រូវការនូវកិច្ចការពារពិសេស** រួមមាន កុមារកំព្រា កុមារដែលត្រូវបានគេបោះបង់ចោល កុមាររងគ្រោះដោយជំងឺអេដស៍ និងមេរោគអេដស៍ កុមាររងគ្រោះដោយការរំលោភបំពាន កុមាររងគ្រោះដោយការកេងប្រវ័ញ្ចពលកម្ម កុមារដែលរស់នៅតាមចិញ្ចើមថ្នល់ កុមារញៀនថ្នាំ ឬកុមារដែលមិនទទួលបាននូវតម្រូវការជាមូលដ្ឋាន ។

**៦- កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។

**៧- គ្រួសារ** សំដៅដល់ឪពុកម្តាយបង្កើតរបស់កុមារ អ្នកអាណាព្យាបាលស្របច្បាប់ និង ញាតិលោហិត ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកុមារ ។

**៨- ស្ថានភាពប្រឈមគ្រោះថ្នាក់** សំដៅដល់ស្ថានភាពមួយដែលអាចបណ្តាលឱ្យកុមារបែកចេញពីគ្រួសារ រួមទាំងស្ថានភាពនានាដែលមានរៀបរាប់នៅក្នុងប្រការ ៥ នៃប្រកាសនេះ ។

**៩- ការថែទាំជំនួស** សំដៅដល់ការថែទាំដែលផ្តល់ទៅឱ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**១០- អ្នកគាំទ្រគ្រួសារ** សំដៅដល់ជនដែលទទួលបានការបណ្តុះបណ្តាល ហើយធ្វើការក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីកំណត់រកកុមារ និងគ្រួសារ ដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ ឬចាត់វិធានការដើម្បីដោះស្រាយ ប្រសិនបើមានករណីបែបនេះបញ្ជូនមក និងធ្វើការតាមដានបន្តតាមរយៈការជួយកុមារ និង ឬគ្រួសារ ។

**១១- ភ្នាក់ងារ ឬ មន្ត្រីសង្គមកិច្ច** សំដៅដល់ជនដែលបានទទួលការបណ្តុះបណ្តាល និងមានអាជីពការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឬថ្នាក់រាជធានី ខេត្ត ដើម្បីផ្តល់នូវអភិបាលកិច្ចដល់អ្នកគាំទ្រគ្រួសារ និងជួយចាត់ចែងដោះស្រាយករណីលំបាកៗ ។

**១២- អាណាព្យាបាលស្របច្បាប់** សំដៅដល់ការទុកដាក់កុមារជាមួយជនណាម្នាក់ ដែលត្រូវបានកំណត់ដោយមរតកសាសន៍របស់ឪពុកម្តាយ ឬតុលាការជ្រើសតាំងជនណាម្នាក់ធ្វើជាអ្នកអាណាព្យាបាល ដើម្បីអនុវត្ត

សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា កាលណាគ្មានអ្នកអនុវត្តអំណាចមេបា ដោយអនុលោមតាមក្រមរដ្ឋប្បវេណី ។

១៣- **អ្នកអាណាព្យាបាល** សំដៅដល់ជនណាម្នាក់ដែលត្រូវបានកំណត់ដោយមរតកសាសន៍របស់ឪពុកម្តាយ ឬជ្រើសតាំងដោយតុលាការ ឱ្យអនុវត្តអំណាចមេបាដោយអនុលោមទៅតាមក្រមរដ្ឋប្បវេណី ។

១៤- **សុំកូនពេញលេញ** សំដៅដល់សេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់ក្នុងការទុកដាក់កុមារ និងបង្កើតឱ្យមានទំនាក់ទំនងឪពុកម្តាយកូនជាអចិន្ត្រៃយ៍រវាងកូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកុមារ និងឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់កុមារ ។

១៥- **សុំកូនធម្មតា** សំដៅដល់សេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់ក្នុងការទុកដាក់កុមារ និងបង្កើតឱ្យមានទំនាក់ទំនងឪពុកម្តាយ និងកូនជាអចិន្ត្រៃយ៍ រវាងកូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម ដោយមិនបានបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកុមារ និងឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់កុមារ ។

១៦- **ការថែទាំក្នុងមណ្ឌល** សំដៅដល់ការចាត់ចែងរៀបចំឱ្យកុមាររស់ក្រោមការថែទាំរបស់បុគ្គលិក ដែលទទួលប្រាក់បៀវត្សរ៍សម្រាប់ថែទាំកុមារ ឧទាហរណ៍ដូចជា មណ្ឌលកុមារកំព្រា មណ្ឌលស្តារនីតិសម្បទា មណ្ឌលផ្តល់កិច្ចការពារដល់កុមារ ។ កុមារដែលរស់នៅក្រោមការរៀបចំបែបនេះទទួលបាននូវការថែទាំពេញម៉ោងក្នុងរយៈពេលមួយសមស្រប ។

១៧- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចសម្រាប់ចិញ្ចឹមថែទាំ និងផ្តល់នូវតម្រូវការជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬគ្មានឪពុក ឬគ្មានម្តាយ ឬកុមារដែលត្រូវបោះបង់ចោល ឬកុមារដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាល ពុំមានលទ្ធភាពផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ ។

១៨- **ផែនការអចិន្ត្រៃយ៍** សំដៅដល់កិច្ចខិតខំប្រឹងប្រែងរកគ្រួសារមួយឱ្យកុមារ ដើម្បីរស់នៅជាមួយជាអចិន្ត្រៃយ៍តាមរយៈការទុកដាក់ជាមួយញាតិ ជាមួយអាណាព្យាបាលក្នុងប្រទេស សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស ។

# ជំពូកទី ២

## ស្ថានភាពប្រឈមគ្រោះថ្នាក់ និងតម្រូវការសម្រាប់កិច្ចអន្តរាគមន៍

**ប្រការ ៥.-**

ស្ថានភាពលំបាកដែលអាចធ្វើឱ្យកុមារប្រឈមគ្រោះថ្នាក់បែកចេញពីគ្រួសារមានជាអាទិ៍:

១- កុមារដែលគ្មានឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៅជាមួយ ។

២- ការបែកចេញពីគ្រួសារ ឬស្ថានភាពគំរាមកំហែងដែលអាចបណ្តាលឱ្យកុមារបែកចេញពីគ្រួសារតាមរយៈការបោះបង់កុមារចោល ការជាប់ពន្ធនាគារ ការជួញដូរ ឬការធ្វើចំណាកស្រុក ។

៣- ការប្រព្រឹត្តអំពើហិង្សា ឬ ការគម្រាមបង្កអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬការបោះបង់ ឬការកេងប្រវ័ញ្ចគ្រប់រូបភាពដូចជាការលក់ ឬជួលកុមារជាដើម ។

៤- កុមារដែលឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកុមារ ដោយសារការខ្វះខាតនូវតម្រូវការចាំបាច់ និងសេវាមូលដ្ឋានដូចជា ទីជម្រក ចំណីអាហារ ការអប់រំ និងការថែទាំសុខភាព ។

៥- កុមារ ឬអ្នកថែទាំកុមារមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាពដែលធ្វើឱ្យកុមារមិនអាចទទួលបានការថែទាំសមស្រប ។

៦- គ្រួសារដែលញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗ ដែលមិនអាចផ្ដល់ការថែទាំសមស្របដល់កុមារ ។

៧- កុមារកំពុងប្រឈម ឬកំពុងមានទំនាស់នឹងច្បាប់ ។

**ប្រការ ៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានសមាជិកស្ថិតក្នុងសមាសភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) មានភារកិច្ចចុះពិនិត្យកុមារ ឬគ្រួសារដែលកំពុងជួបបញ្ហាប្រឈមគ្រោះថ្នាក់ ដូចមានចែងក្នុងប្រការ ៥ ហើយត្រូវធ្វើការប៉ាន់ប្រមាណស្ថានភាពប្រឈមគ្រោះថ្នាក់ និងភាពខ្លាំងរបស់គ្រួសារនោះ ។ ក្នុងករណីពិនិត្យឃើញថា កុមារ ឬគ្រួសារស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ ហើយកុមារ ឬគ្រួសារមិនអាចដោះស្រាយបានត្រូវបើកករណីដើម្បីផ្ដល់សេវាជំនួយនានាដោយមានកិច្ចសហការ និងអន្តរាគមន៍ពីគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សារាជធានី ខេត្ត ព្រមទាំងកិច្ចសហប្រតិបត្តិការ ការគាំទ្របច្ចេកទេស និងការផ្ដល់សេវាជាដំបូងពីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ និងបន្ទាប់មកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ។

## ជំពូកទី ៣
## តួនាទី និងភារកិច្ចរបស់អង្គភាពពាក់ព័ន្ធ

**ប្រការ ៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ (គ.ក.ន.ក) មានភារកិច្ចដូចតទៅ :

១- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលរាល់ការប្រាស្រ័យទាក់ទងគ្នាជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត វត្តអារាម ទីកន្លែងសាសនានានា និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយកុមារ និងគ្រួសារ ពាក់ព័ន្ធនឹងការអនុវត្តប្រកាសនេះនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

២- ប្រមូលទិន្នន័យកុមារងាយរងគ្រោះនៅក្នុងឃុំ សង្កាត់ ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំធ្វើផែនការវិនិយោគប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងផែនការអភិវឌ្ឍឃុំ សង្កាត់ ដើម្បីកៀរគរថវិកា និងបច្ចេកទេសពីស្ថាប័នពាក់ព័ន្ធ និងរាយការណ៍ជូនគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ។

៣- កំណត់អំពីអត្តសញ្ញាណ និងបាន់ប្រមាណអំពីស្ថានភាពកុមារ និងគ្រួសារដែលកំពុងស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ ធ្វើផែនការស្វែងរកសេវាចាំបាច់នានាសម្រាប់កុមារ និងគ្រួសារតាមដានដំណើរការវិវឌ្ឍរបស់ពួកគេ ដើម្បីថែរក្សាកុមារឱ្យរស់នៅជាមួយគ្រួសារ និងសម្រេចទុកដាក់កុមារជាបណ្តោះអាសន្នជាមួយញាតិក្នុងឃុំ សង្កាត់ជាមួយគ្នាប្រសិនបើចាំបាច់។

៤- ធ្វើការជាមួយគ្រួសារកុមារផ្ទាល់ និងសហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីត្រៀមលក្ខណៈរបស់គ្រួសារក្នុងការទទួលកុមារត្រឡប់មកវិញតាមដានសេវាបង្រួបបង្រួមគ្រួសារ និងសមាហរណកម្មកុមារទៅក្នុងគ្រួសារ ដើម្បីឱ្យកុមារបានរស់នៅជួបជុំជាមួយគ្រួសាររបស់ខ្លួនវិញ។

៥- ត្រូវរៀបចំទុកដាក់កុមារ ដែលត្រូវបោះបង់នៅក្នុងសហគមន៍ជាបណ្តោះអាសន្ននៅកន្លែងមួយមានសុវត្ថិភាពជាមួយញាតិ ឬទុកដាក់តាមការថែទាំជំនួសក្នុងសហគមន៍ដោយសហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ។ ជម្រើសចុងក្រោយត្រូវបញ្ជូនកុមារទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ករណីមិនអាចរកកន្លែងទុកដាក់កុមារតាមការថែទាំដោយញាតិ និងការថែទាំក្នុងសហគមន៍បាន។

៦- បំពេញ រក្សា និងចម្លងជូនអាជ្ញាធរពាក់ព័ន្ធ នូវទម្រង់ពាក់ព័ន្ធនានាដែលមានភ្ជាប់ជាមួយប្រកាសនេះទៅតាមដំណាក់កាល នៃការវិវឌ្ឍរបស់ករណីកុមារនីមួយៗ។

**ប្រការ ៨.-**

ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ :

១- ប្រមូលទិន្នន័យកុមារងាយរងគ្រោះ ដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍ នៅក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា រាជធានី ខេត្ត ក្នុងការរិះរកយុទ្ធសាស្ត្រ និងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីការពារ និងថែទាំកុមារទាំងនោះ និងដើម្បីរាយការណ៍ទិន្នន័យទាំងនេះជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា រាជធានី ខេត្ត។

២- ផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងការណែនាំបច្ចេកទេសដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ។

៣- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលការប្រាស្រ័យទាក់ទងជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ វត្តអារាម ទីកន្លែងសាសនា និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូនានា ដើម្បីផ្តល់សេវាដល់គ្រួសារ ដែលជាករណីត្រូវការសេវារក្សាកុមារក្នុងគ្រួសារ និងសេវាបង្រួបបង្រួមគ្រួសារ។

៤- គ្រប់គ្រងដោយផ្ទាល់លើករណីកុមារដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រួមមានករណីកុមារទទួលការថែទាំដោយឪពុកម្តាយធម៌ដែលមិនមែនជាញាតិ ករណីទុកដាក់កុមារឆ្លងក្រុង ស្រុក ខណ្ឌ ឬឆ្លងរាជធានី ខេត្ត ករណីពិបាកៗ ករណីកុមារដែលត្រូវបានទុកដាក់ក្នុងមណ្ឌល ឬបម្រុងនឹងទុកដាក់ក្នុងមណ្ឌល និងកុមារដែលត្រូវធ្វើផែនការអចិន្ត្រៃយ៍។

៥- តាមដានការបញ្ជូនករណី សេវានានាដែលបានផ្តល់ និងលទ្ធផលការងារ ដែលការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ សម្រេចបាន ហើយធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។

៦- បំពេញ រក្សា និងចម្លងជូនអ្នកពាក់ព័ន្ធនូវទម្រង់ពាក់ព័ន្ធនានា ដែលមានភ្ជាប់ជាមួយប្រកាសនេះ ទៅតាមដំណាក់កាល នៃការវិវឌ្ឍន៍របស់ករណីកុមារនីមួយៗ។

៧- ចូលរួមក្នុងការត្រួតពិនិត្យ និងតាមដានការអនុវត្តបទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ និងតាមមណ្ឌល។

**ប្រការ ៩.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅថ្នាក់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវមានភារកិច្ចដូចតទៅ ៖

១- ជួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ក្នុងការកំណត់អំពីអត្តសញ្ញាណ និងប៉ាន់ប្រមាណអំពីស្ថានភាពកុមារ និងគ្រួសារដែលកំពុងស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ ក្នុងករណីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មិនអាចបំពេញការងារនេះបាន។

២- ធ្វើទំនាក់ទំនង និងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ដើម្បីប្រមូល និងវិភាគទិន្នន័យ ព្រមទាំងបញ្ចូលបញ្ហាកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងផែនការបី(០៣)ឆ្នាំ រំកិលរបស់ក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់ការគាំទ្រ និងកៀរគរធនធានសម្រាប់

ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការ និងរកសេវាចាំបាច់នានាសម្រាប់កុមារ និងគ្រួសារ និងដើម្បីអនុវត្តភារកិច្ច ដូចមានចែងក្នុងប្រការ៧។

៣- សហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ក្នុងការបណ្តុះបណ្តាល និងកសាងសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ អំពីនីតិវិធី និងទម្រង់បែបបទនានាក្នុងប្រកាសនេះ ។

៤- ធ្វើសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត តាមរយៈគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ខេត្ត និងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបំពេញការងារពាក់ព័ន្ធសុខុមាលភាពកុមារ និងគ្រួសារ ដើម្បីអនុវត្តកិច្ចការដូចបានរៀបរាប់ខាងលើនេះ ។

**ប្រការ ១០.-**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវមានភារកិច្ចដូចតទៅ :

១- ធ្វើបញ្ជីបច្ចុប្បន្នភាពនៃនីតិបុគ្គលផ្តល់ការថែទាំកុមារ អង្គការជាតិ-អន្តរជាតិ និងមណ្ឌលថែទាំកុមារទាំងអស់ដែលទទួលបានការអនុញ្ញាតិឱ្យផ្តល់ការថែទាំជំនួសចំពោះកុមារ ។

២- ថែរក្សា និងធ្វើបច្ចុប្បន្នភាពទិន្នន័យកុមារងាយរងគ្រោះ កុមារកំពុងរស់ក្នុងមណ្ឌល និងប្រភេទការថែទាំផ្សេងទៀតរួមទាំងកុមារដែលបានចាកចេញពីការថែទាំជំនួសនៅក្នុងរាជធានី ខេត្តរបស់ខ្លួន និងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ដើម្បីរិះរកយុទ្ធសាស្ត្រ និងការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។

៣- អនុវត្តផែនការអចិន្ត្រៃយ៍សម្រាប់ករណីកុមារទាំងអស់នៅក្នុងរាជធានី ខេត្ត ដូចមានចែងក្នុងជំពូកទី ៧ នៃប្រកាសនេះ ។

៤- ធ្វើការស្វែងរកឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារដែលត្រូវបានបោះបង់ចោល ដូចមានចែងនៅក្នុងប្រការ ២០ ជំពូកទី ៥ នៃប្រកាសនេះ ។

៥- ជួយឧបត្ថម្ភគាំទ្រ និងណែនាំដល់មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ និង សម្របសម្រួលទំនាក់ទំនងជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដទៃទៀតសម្រាប់ករណីឆ្លងរាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត ។

៦- ពង្រីកប្រភពធនធាន ដើម្បីពង្រឹងការថែទាំកុមារតាមគ្រួសារ តាមរយៈមធ្យោបាយនានា ដូចជាការផ្តួចផ្តើមគំនិតនៅតាមសហគមន៍ ជំនួយទ្វេភាគី អ្នកដឹកនាំសាសនាដែលទទួលបានការបណ្តុះបណ្តាល (ដូចជាព្រះសង្ឃ) និងសហប្រតិបត្តិការជាមួយមន្ទីរដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល

និងផ្នែកឯកជននានា ដើម្បីផ្តល់ការឧបត្ថម្ភគាំទ្រ ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដល់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តភារកិច្ចដែលមានចែងក្នុងប្រកាសនេះ ។

៧- ផ្សព្វផ្សាយការយល់ដឹងនៅតាមសហគមន៍អំពីគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារ ព្រមទាំងលើកកម្ពស់ ជ្រើសរើស បណ្តុះបណ្តាល និងឧបត្ថម្ភគាំទ្រគ្រួសារទាំងឡាយណា ដែលមានបំណងធ្វើជាគ្រួសារអចិន្ត្រៃយ៍សម្រាប់កុមារ ។

៨- ប្រមូលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពបញ្ជីកុមារដែលត្រូវបោះបង់ចោល និងបញ្ជីឈ្មោះគ្រួសារដែលត្រូវទទួលយកសម្រាប់ការទុកដាក់កុមារជាអចិន្ត្រៃយ៍ នៅតាមរាជធានី ខេត្ត រួមមាន គ្រួសារដែលទទួលបានការអនុម័តយល់ព្រម គ្រួសារដែលកំពុងអនុវត្តដំណើរការផ្លូវច្បាប់ គ្រួសារដែលតម្រូវឱ្យមានការស៊ើបអង្កេត និងគ្រួសារដែលបានទទួលការបណ្តុះបណ្តាលរួច ។

៩- ធ្វើការសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត មន្ទីរធម្មការ និងសាសនា អង្គការមិនមែនរដ្ឋាភិបាលដៃគូ និងអង្គភាពពាក់ព័ន្ធនានា ដើម្បីស្វែងរកធនធានថវិកា សម្ភារៈ និងការគាំទ្របច្ចេកទេស សម្រាប់ជួយដល់កុមារអាយុច្រើនដែលមិនអាចរកគ្រួសារអចិន្ត្រៃយ៍បាន ដើម្បីធានាថា កុមារទាំងនេះទទួលបាននូវការបណ្តុះបណ្តាលជំនាញបំណិនជីវិត និងជំនាញវិជ្ជាជីវៈនានា មុនពេលឈានដល់ភាពពេញវ័យ ។

១០- បំពេញ រក្សា និងចម្លងជូនផ្នែកពាក់ព័ន្ធនូវទម្រង់ពាក់ព័ន្ធនានាដែលមានភ្ជាប់ជាមួយប្រកាសនេះទៅតាមដំណាក់កាល នៃការវិវឌ្ឍន៍របស់ករណីកុមារនីមួយៗ ។

១១- ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងតាមដានការអនុវត្តបទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ ។

១២- តាមដានលើសេវានានាដែលបានផ្តល់ និងធ្វើការបូកសរុបរបាយការណ៍លទ្ធផលការងារសម្រេចបានក្នុងតំបន់ផ្តល់សេវារបស់ខ្លួន ជាប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងឆ្នាំ ជូនគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងចែកជូនព័ត៌មានសំខាន់ៗដល់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ នៅតំបន់គ្របដណ្តប់របស់ខ្លួន ។

១៣- ប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិលសមស្របតាមគោលនយោបាយដែលគិតគូរដល់កុមារ និងគ្រួសារមេត្រី ។

**ប្រការ ១១.-**

ក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្តមានភារកិច្ចដូចតទៅ :

១- ធ្វើទំនាក់ទំនង និងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីជួយគាំទ្រ និងកៀរគរធនធានសម្រាប់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើផែនការ និងរកសេវាចាំបាច់នានាសម្រាប់កុមារ និងគ្រួសារ ដើម្បីអនុវត្តតួនាទី ដែលមានចែងក្នុងប្រការ ៨ និង ៩។

២- ធ្វើទំនាក់ទំនង និងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីប្រមូល និងវិភាគទិន្នន័យ ព្រមទាំងបញ្ចូលបញ្ហាកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំ និងផែនការបី (០៣) ឆ្នាំរំកិលរបស់រាជធានី ខេត្ត ដើម្បីគាំទ្រ និងកៀរគរធនធានសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំផែនការ និងរកសេវាចាំបាច់នានាសម្រាប់កុមារ និងគ្រួសារ និងដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ៩ ។

៣- សហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ក្នុងការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ អំពីសុខុមាលភាពកុមារ និងគ្រួសារ ។

៤- ធ្វើសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មន្ទីរពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ ។

**ប្រការ ១២.-**

នាយកដ្ឋានសុខុមាលភាពកុមាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចដូចតទៅ:

១- គ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីច្បាប់ទាក់ទងនឹងការអនុវត្តគោលយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ ។

២- លើកគម្រោងថវិកា ធ្វើការបណ្តុះបណ្តាល និងផ្តល់ជំនួយបច្ចេកទេសដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តនីតិវិធីនានា ដែលមានចែងក្នុងប្រកាសនេះ ។

៣- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ និងអន្តរជាតិ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សា ឃុំ សង្កាត់ ចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងការងារសុខុមាលភាពកុមារ ។

៤- រៀបចំ និងថែទាំប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ស្តីពីសកម្មភាពសុខុមាលភាពកុមារទូទាំងប្រទេស រួមមានទិន្នន័យកុមារត្រូវបានគេបោះបង់ចោល កុមារដែលត្រូវបានបង្រួបបង្រួមឱ្យរស់នៅក្នុងគ្រួសារវិញ កុមារស្ថិតក្នុងការថែទាំជំនួសចំពោះកុមារ កុមារដែលត្រូវការផែនការអចិន្ត្រៃយ៍ កុមារដែលមានលក្ខណៈវិនិច្ឆ័យ

គ្រប់គ្រាន់សម្រាប់សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស ហើយត្រូវរៀបចំបញ្ជីកុមារដែលបានសុំក្នុងប្រទេស និងសុំអន្តរប្រទេស ។

៥- ផ្សព្វផ្សាយការយល់ដឹងនៅតាមសហគមន៍ អំពីគោលនយោបាយ ស្តីពីថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារតាមសហគមន៍ និងលើកកម្ពស់ ជ្រើសរើស បណ្តុះបណ្តាល ព្រមទាំងជួយឧបត្ថម្ភគាំទ្រគ្រួសារទាំងឡាយណា ដែលមានបំណងចិញ្ចឹមកុមារជាលក្ខណៈអចិន្ត្រៃយ៍ និងរក្សាបញ្ជីគ្រួសារទាំងអស់នោះនៅថ្នាក់ជាតិ ។

៦- ផ្សព្វផ្សាយ និងលើកកម្ពស់អំពីសិទ្ធិកុមារ គោលនយោបាយ និងបទដ្ឋាននានាទាក់ទងនឹងសុខុមាលភាពកុមារដល់ថ្នាក់មូលដ្ឋាន និងសហគមន៍ ។

៧- ផ្តល់ជំនួយបច្ចេកទេសដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ក្នុងការត្រួតពិនិត្យ និងតាមដានការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ និងតាមមណ្ឌល ។

៨- ប្រើប្រាស់ថវិកាជាតិ មូលនិធិទ្រទ្រង់វិស័យសុខុមាលភាពកុមារ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល សមស្របតាមគោលនយោបាយ ដែលគិតគូរដល់កុមារ និងគ្រួសារមេត្រី និងលើកកម្ពស់ការបង្វែរសេវារបស់អង្គការមិនមែនរដ្ឋាភិបាលឱ្យស្របនឹងគោលដៅនៃប្រកាសនេះ ។

## ជំពូកទី ៤
## ការផ្តល់សេវាថែរក្សារគ្រួសារ

**ប្រការ ១៣.-**

ក្នុងករណីកុមារកំពុងប្រឈមមុខនឹងស្ថានភាពត្រូវបែកពីគ្រួសារដោយសារស្ថានភាពប្រឈម ចាំបាច់ត្រូវការពារគ្រួសារមិនឱ្យមានការបែកបាក់ តាមរយៈការផ្តល់សេវាគាំទ្រគ្រួសារ ។ សេវាទាំងនោះត្រូវផ្តល់ឱ្យដោយផ្អែកទៅតាមការប៉ាន់ប្រមាណលើស្ថានភាពប្រឈមគ្រោះថ្នាក់នោះ និងធនធាននានាដែលគ្រួសារមាន ក្នុងការដោះស្រាយការប្រឈមគ្រោះថ្នាក់ទាំងនោះ ។ សេវាដែលផ្តល់ឱ្យទាំងនោះធ្វើឡើងក្នុងគោលបំណងជួយឱ្យគ្រួសារមានស្ថេរភាព និងបង្កើនសមត្ថភាពគ្រួសារ ដើម្បីឱ្យគ្រួសារអាចថែទាំកុមារបាន ទាំងសម្រាប់រយៈពេលខ្លី និងទាំងសម្រាប់រយៈពេលវែង ។

**ប្រការ ១៤.-**

ក្នុងករណីទទួលបានរបាយការណ៍អំពីកុមាររងាយរងគ្រោះ ឬស្ថានភាពប្រឈមគ្រោះថ្នាក់របស់កុមារណាម្នាក់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម:

១- ចុះសួរសុខទុក្ខកុមារ និងគ្រួសារ ដើម្បីប៉ាន់ប្រមាណពីស្ថានភាពជាក់ស្តែងក្នុងគ្រួសារ ព្រមទាំងកំណត់ឱ្យច្បាស់ ថាតើគ្រួសារនោះមានលទ្ធភាពដោះស្រាយស្ថានភាពលំបាកដោយខ្លួនឯងបានឬចាំបាច់ត្រូវការឱ្យមានអន្តរាគមន៍ពីខាងក្រៅ ។

២- ក្នុងករណីចាំបាច់ត្រូវមានអន្តរាគមន៍ពីខាងក្រៅ ត្រូវរៀបចំធ្វើផែនការសេវា ដើម្បីឱ្យកុមារនិងគ្រួសារទទួលបានសេវាសមស្រប ។

៣- ទំនាក់ទំនងស្វែងរកសេវាសម្រាប់ជួយគ្រួសារ ក្នុងគោលដៅថែរក្សាកុមារឱ្យបានរស់នៅជួបជុំគ្នាជាមួយគ្រួសារ ។

៤- ត្រួតពិនិត្យ តាមដានដំណើរការវិវឌ្ឍរបស់កុមារ និងគ្រួសារឱ្យបានទៀងទាត់ ដោយផ្អែកលើគោលដៅដែលបានកំណត់នៅក្នុងផែនការសេវា ។

ចំពោះករណីដែលពិបាកដោះស្រាយ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទាក់ទងជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសាសនាដែលទទួលបានការបណ្តុះបណ្តាល ដើម្បីពិគ្រោះយោបល់និងស្វែងរកជំនួយបន្ថែម ។

## ប្រការ ១៥.-

នីតិវិធីសម្រាប់ផ្តល់សេវាថែរក្សាកុមារក្នុងគ្រួសាររួមមានៈ

១- ពេលធ្វើការប៉ាន់ប្រមាណគ្រួសារដំបូង ការការពារសុវត្ថិភាពកុមារ និងអ្នកថែទាំកុមារជាប្រការដែលត្រូវអនុវត្តជាប្រចាំ ។

២- ក្នុងករណីអាចមានគ្រោះថ្នាក់ភ្លាមៗដល់សុវត្ថិភាពរបស់កុមារ ឬអ្នកថែទាំកុមារ ចាំបាច់ត្រូវបំបែកកុមារ ឬអ្នកថែទាំកុមារចេញពីស្ថានភាពគ្រោះថ្នាក់នោះ ។ ចំពោះករណីដែលមនុស្សពេញវ័យជាអ្នកបង្កគ្រោះថ្នាក់ដល់កុមារ និង ឬអ្នកថែទាំកុមារ ត្រូវពិចារណា និងដោះស្រាយ ដោយបំបែកមនុស្សពេញវ័យដែលបង្កគ្រោះថ្នាក់ចេញពីគ្រួសារ មុនពេលពិចារណាចំពោះការបំបែកកុមារចេញពីគ្រួសារ ។

៣- រាល់ការបំបែកសមាជិកគ្រួសារ ត្រូវធ្វើឡើងដោយមានការជួបប្រជុំពិគ្រោះយោបល់រួមគ្នារវាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ និងត្រូវចងក្រងជាឯកសារឱ្យបានច្បាស់លាស់ ។ ការទុកដាក់កុមារនៅក្រៅរង្វង់គ្រួសាររបស់ខ្លួន ត្រូវអនុលោមតាមអាទិភាពនៃការទុកដាក់ជាមួយសាច់ញាតិ ការថែទាំជំនួសតាមសហគមន៍ និងការថែទាំជំនួសតាមមណ្ឌល ។

៤- ក្នុងដំណើរការនៃការបំបែក ត្រូវសុំឱ្យមានការធ្វើអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើពិនិត្យឃើញថា ករណីនោះអាចនឹងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

៥- ក្នុងកំឡុងពេលកុមារស្ថិតក្នុងការថែទាំជំនួសបណ្តោះអាសន្ន ត្រូវផ្តល់សេវាបង្រួបបង្រួមគ្រួសារ និងសេវារក្សាកុមារក្នុងគ្រួសារដល់កុមារ និងគ្រួសារ ។

## ប្រការ ១៦.-

កិច្ចការពារសុវត្ថិភាពកុមារ និងសមាជិកគ្រួសារកុមាររួមមានៈ

១- គ្រប់ករណីដែលបានសម្រេចជាស្ថាពរនូវគោលដៅដែលបានកំណត់នៅក្នុងផែនការសេវាគ្រួសារ ហើយនៅពេលបានដោះស្រាយការប្រឈមគ្រោះថ្នាក់របស់កុមារ និងគ្រួសាររួច ត្រូវបិទករណីនោះ ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវបំពេញផ្នែកខាងក្រោយនៃទម្រង់ផែនការសេវាគ្រួសារ ដោយមានបញ្ជាក់អំពីកាលបរិច្ឆេទ និងមូលហេតុនៃការបិទករណី ។

២- ចំពោះគ្រួសារដែលមានកូនស្ថិតក្នុងវ័យកុមារច្រើនក្នុងបន្ទុកកំពុងទទួលបានសេវានានា ការផ្តល់ជំនួយអាចនឹងបន្តរហូតដល់កុមារទាំងអស់ក្នុងគ្រួសាររួចផុតពីការប្រឈមគ្រោះថ្នាក់ ។

៣- ក្នុងករណីពិនិត្យ និងវាយតម្លៃឃើញថា ទោះបីជាមានការខិតខំប្រឹងប្រែងជួយជ្រោមជ្រែងអន្តរាគមន៍ក្នុងរយៈពេលមួយសមស្របយ៉ាងណាក៏ដោយ ក៏បញ្ហាកុមារ និងគ្រួសារនៅតែមិនអាចដោះស្រាយបាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវបញ្ជូនករណីនេះទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ដើម្បីស្នើសុំឱ្យធ្វើផែនការអចិន្ត្រៃយ៍។ បន្ទាប់មកការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេចបើកករណីធ្វើផែនការអចិន្ត្រៃយ៍។

៤- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ អាចទាក់ទងជាមួយមន្ទីរធម្មការ និងសាសនា ឬអ្នកដឹកនាំសាសនា អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ឱ្យរួមចំណែកក្នុងការឧបត្ថម្ភគាំទ្រដល់គ្រួសារដែលប្រឈមការបែកបាក់។

## ជំពូកទី ៥

## ការផ្តល់សេវាបង្រួបបង្រួមគ្រួសារ

### ប្រការ ១៧.-

កុមារដែលរស់នៅបែកពីគ្រួសារ ដោយសារការធ្វើចំណាកស្រុក ការជួញដូរ ការទុកដាក់ឱ្យរស់នៅតាមការថែទាំជំនួស ការបោះបង់ចោល ឬមូលហេតុផ្សេងទៀត ត្រូវទទួលបាននូវសេវាចាំបាច់ ដើម្បីឱ្យកុមារបានទៅរស់នៅជួបជុំជាមួយគ្រួសារវិញ។ ការផ្តល់សេវាបង្រួបបង្រួមនេះ មិនអនុវត្តចំពោះកុមារដែលត្រូវបានទុកដាក់ជាអចិន្ត្រៃយ៍ ឬទុកដាក់បណ្តោះអាសន្នជាមួយញាតិ តាមរយៈការព្រមព្រៀងទាំងសងខាងរវាងឪពុកម្តាយ ហើយកំពុងត្រូវបានគេចាត់ទុកដូចជាកូនបង្កើតនោះទេ។

### ប្រការ ១៨.-

ចំពោះកុមារកំពុងរស់នៅក្នុងការថែទាំជំនួស ដូចជារស់នៅជាមួយញាតិ សហគមន៍ និងក្នុងមណ្ឌល ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធីបង្រួបបង្រួមគ្រួសារ ដោយចុះពិនិត្យប៉ាន់ប្រមាណអំពីស្ថានភាព និងតម្រូវការរបស់កុមារ និងស្ថានភាពគ្រួសារ ក្នុងគោលបំណងសមាហរណកម្មកុមារទៅរស់នៅជួបជុំគ្រួសារ និងសហគមន៍វិញ។ ចំពោះកុមារដែលរស់នៅក្នុងរាជធានី ខេត្ត មួយផ្សេងពីគ្រួសាររបស់ខ្លួន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងនោះ ដើម្បីផ្ទេរករណីឱ្យអនុវត្តការងារតាមដាន និងផ្តល់សេវាបន្តចាំបាច់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវត្រៀមលក្ខណៈរបស់កុមារសម្រាប់ការបង្រួបបង្រួម

TH

គ្រួសារ ហើយបន្ទាប់មកត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលគ្រួសារកុមាររស់នៅ ដើម្បីជួយដល់គ្រួសារនោះ ឱ្យត្រៀមលក្ខណៈជាមុន មុននឹងកុមារមករស់នៅក្នុងគ្រួសារវិញ។ ករណីចាំបាច់ ត្រូវផ្តល់សេវាសមស្របនានាដែលអាចឱ្យគ្រួសារកុមារមានលទ្ធភាពទទួលយកកុមារមកថែទាំក្នុងគ្រួសារវិញ។

២- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវប្រជុំពិភាក្សារកវិធីដើម្បីផ្សាំកុមារ និងគ្រួសារបន្តិច១ម្តង មុននឹងធ្វើសមាហរណកម្ម ប្រសិនបើចាំបាច់។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវពិភាក្សាគ្នាអំពីតម្រូវការចាំបាច់របស់កុមារ និងគ្រួសារ ក្រោយពេលបង្រួបបង្រួមគ្រួសារ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏អាចត្រៀមលក្ខណៈរបស់សហគមន៍ផងដែរ ចំពោះការវិលត្រឡប់របស់កុមារ។

៣- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ធ្វើសមាហរណកម្មកុមារទៅគ្រួសារ បន្ទាប់ពីកុមារ និងគ្រួសារបានត្រៀមលក្ខណៈរួច។

៤- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ធ្វើការតាមដានលើការរួមរស់ជាមួយគ្នាឡើងវិញរវាងកុមារ និងគ្រួសារយ៉ាងតិចបីដងក្នុងមួយឆ្នាំ ហើយត្រូវបិទករណីនៅពេលដែលសមស្រប។ ក្នុងករណីការបង្រួបបង្រួមគ្រួសារមិនទទួលបានជោគជ័យ ត្រូវអនុវត្តផែនការអចិន្ត្រៃយ៍សម្រាប់ករណីនេះ ដោយមានការសម្រេចពីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។

៥- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវធ្វើការបូកសរុបលទ្ធផលករណី និងធ្វើរបាយការណ៍ ផ្ញើទៅនាយកដ្ឋានសុខុមាលភាពកុមារ។

ការបង្រួបបង្រួមគ្រួសារ គឺធ្វើឡើងដើម្បីឧត្តមប្រយោជន៍កុមារ លើកលែងតែទង្វើបែបនេះធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់កុមារ។

**ប្រការ ១៩.-**

នីតិវិធីសម្រាប់កុមារដែលត្រូវបោះបង់ចោលត្រូវអនុវត្តដូចខាងក្រោម :

១- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវប្រកាសផ្សព្វផ្សាយ និងជូនដំណឹងដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យដឹងថា ក្នុងករណីទទួលបានព័ត៌មានប្រទះឃើញ ឬទទួលកុមារ ដែលត្រូវគេបោះបង់ ត្រូវផ្ដល់ព័ត៌មាន ឬបញ្ជូនកុមារជាបន្ទាន់ទៅប្រធានភូមិ ឬគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

២- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មានភារកិច្ចចម្បងក្នុងការស្រាវជ្រាវរកគ្រួសារ ឬអាណាព្យាបាលរបស់កុមារដែលត្រូវគេបោះបង់នៅក្នុងឃុំ សង្កាត់ ដោយសហការជាមួយមន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ។ ការស្រាវជ្រាវត្រូវធ្វើឡើងជាបន្ទាន់ បន្ទាប់ពីបានប្រទះឃើញកុមារ ឬទទួលព័ត៌មានពីប្រធានមណ្ឌលថែទាំកុមារស្របពេលដែលប្រធានភូមិ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទុកដាក់កុមារបណ្ដោះអាសន្នជាមួយសាច់ញាតិជិតបំផុត ឬគ្រួសារផ្សេងទៀតនៅក្នុងសហគមន៍។ ក្នុងករណីទុកដាក់កុមារជាមួយគ្រួសារមិនជាប់សាច់ញាតិ ដែលមិនស្ថិតនៅក្នុងឃុំ សង្កាត់របស់ខ្លួន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ត្រូវជូនដំណឹងទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ។

៣- ក្នុងករណីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ មិនអាចស្វែងរកញាតិ ឬគ្រួសារផ្សេងទៀត ក្នុងសហគមន៍សម្រាប់ថែទាំកុមារបាន ត្រូវសហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ដើម្បីស្វែងរកគ្រួសារចមិឱ្យកុមារជាបណ្ដោះអាសន្ន រហូតដល់ដល់រកបានគ្រួសារអចិន្ត្រៃសម្រាប់កុមារ ។ មធ្យោបាយចុងក្រោយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ត្រូវសហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ដើម្បីដាក់កុមារជាបណ្ដោះអាសន្ននៅក្នុងមណ្ឌល រហូតរកឃើញឪពុកម្ដាយ ឬអាណាព្យាបាលរបស់កុមារ ឬគ្រួសារផ្សេងទៀត សម្រាប់ថែទាំកុមារ ។

៤- ករណីមានកុមារណាម្នាក់ត្រូវបានគេបោះបង់ចោលនៅតាមមណ្ឌល ឬត្រូវបុគ្គលណាម្នាក់នាំមកកាន់មណ្ឌលកុមារកំព្រា ប្រធានមណ្ឌលកុមារកំព្រាត្រូវទុកដាក់កុមារនៅកន្លែងមានសុវត្ថិភាព បំពេញឯកសារទទួលកុមារឱ្យស្នាក់នៅក្នុងមណ្ឌល និងតម្រូវឱ្យបុគ្គលដែលនាំយកកុមារមកមណ្ឌល ( ប្រសិនបើមាន) ចុះហត្ថលេខាទៅលើទម្រង់នោះ។ ប្រធានមណ្ឌល ត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ នៅក្នុងឃុំ សង្កាត់ ដែលកុមារត្រូវប្រទះឃើញ ហើយត្រូវជូនដំណឹងទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ក្នុងរយៈពេល ៧ ( ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលកុមារឱ្យស្នាក់នៅក្នុងមណ្ឌល។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ត្រូវអនុវត្តទៅតាមនីតិវិធីនៃជម្រើសក្នុងការទុកដាក់កុមារ ដូចមានចែងនៅក្នុងគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ និង ជំពូកទី៦នៃប្រកាសនេះ ។

៥- គ្រប់ករណីកុមារដែលត្រូវគេបោះបង់ទាំងអស់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ត្រូវរាយការណ៍ជាបន្ទាន់ជូនការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត បន្ទាប់ពីប្រទះឃើញកុមារ។ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យ និងប៉ាន់ប្រមាណករណីនេះ រួចរៀបចំរបាយការណ៍បញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាបន្ទាន់ក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលរបាយការណ៍ពីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។ បន្ទាប់មកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍អំពីកុមារដែលត្រូវបានគេបោះបង់ដោយមានរូបថតកុមារភ្ជាប់ជាមួយ ផ្ញើជូននាយកដ្ឋានសុខុមាលភាពកុមារ ដើម្បីបញ្ចូលឈ្មោះកុមារក្នុងបញ្ជីកុមារដែលត្រូវបានគេបោះបង់។

៦- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ អាចទាក់ទងជាមួយមន្ទីរធម្មការ និងសាសនា អ្នកដឹកនាំសាសនា អង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីឱ្យចូលរួមក្នុងដំណើរការនេះ។

**ប្រការ ២០.-**

នីតិវិធីស្វែងរកឪពុកម្តាយ អាណាព្យាបាលរបស់កុមារដែលត្រូវបានគេបោះបង់ចោល មានដូចខាងក្រោម :

១- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវទទួលខុសត្រូវជារួមក្នុងការស្វែងរកឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារដែលត្រូវបោះបង់ចោល ដោយសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិនានា ដែលមិនមានកម្មវិធីសុំកូន និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ផ្សេងទៀត។

២- ការស្វែងរកគ្រួសារត្រូវធ្វើជាបន្ទាន់ បន្ទាប់ពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលរបាយការណ៍អំពីកុមារដែលត្រូវបោះបង់ចោល ហើយត្រូវខិតខំប្រឹងប្រែង និងប្រើប្រាស់គ្រប់មធ្យោបាយ ដែលអាចធ្វើទៅបាន រួមទាំងប្រព័ន្ធផ្សព្វផ្សាយ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវបិទប្រកាសស្វែងរកឪពុកម្តាយ ឬអាណាព្យាបាល (ដោយមានរូបថតកុមារ) នៅកន្លែងដែលកុមារត្រូវបានបោះបង់ចោល ឬទីប្រជុំជនផ្សេងទៀត។ សេចក្តីប្រកាសជូនដំណឹងនោះត្រូវចម្លងជូននាយកដ្ឋានសុខុមាលភាពកុមារ។

៣- ការប្រកាសស្វែងរកគ្រួសារត្រូវធ្វើឡើងរយៈពេល ៥ (ប្រាំ)ខែ ជាប់គ្នា ឬអាចបន្តរហូតរកឃើញ។

៤- នៅពេលបញ្ចប់ការស្វែងរក ទោះក្នុងករណីរកឃើញ ឬមិនឃើញឪពុកម្តាយ និង ឬ អាណាព្យាបាលរបស់កុមារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវរៀបចំបញ្ជូនទៅនាយកដ្ឋានសុខុមាលភាពកុមារ នូវឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងពីរដូចខាងក្រោម:

ក. ***របាយការណ៍អំពីការរកឃើញឪពុកម្ដាយ ឬអាណាព្យាបាល :*** ករណីរកឃើញឪពុកម្ដាយ ឬអាណាព្យាបាលនៅពេលស្វែងរក ឬក៏មានជនណាអះអាងថាខ្លួន គឺជាឪពុក ម្ដាយ ញាតិ ឬ អាណាព្យាបាលរបស់កុមារ ជននោះត្រូវផ្ដល់ភស្ដុតាង និងឯកសារគតិយុត្ត ស្ដីពីទំនាក់ទំនង ជាមួយនឹងកុមារ ។ បន្ទាប់មក មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវធ្វើសំណើជូនទៅនាយកដ្ឋានសុខុមាលភាពកុមារ ដើម្បីលុបឈ្មោះកុមារពីបញ្ជីកុមារត្រូវ បោះបង់ចោលដោយប្រើទម្រង់សមស្រប ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវចាត់វិធានការឱ្យមន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ក្រុង ស្រុក ខណ្ឌ សហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ ចុះធ្វើការប៉ាន់ប្រមាណគ្រួសារ និងបង្កើតផែនការសេវារួមគ្នាជាមួយ គ្រួសារ ដើម្បីបង្រួបបង្រួម និងថែរក្សាកុមារក្នុងគ្រួសារនោះ ។

ខ. ***របាយការណ៍អំពីការរកមិនឃើញឪពុកម្ដាយ*** : ករណីខិតខំប្រឹងប្រែងអស់លទ្ធភាពក្នុងការ ស្វែងរកឪពុកម្ដាយ ឬអាណាព្យាបាលរបស់កុមារអស់រយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិន ឃើញ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ អំពីការរកមិនឃើញឪពុកម្ដាយ ឬអាណាព្យាបាលកុមារ ហើយចម្លងមួយច្បាប់ជូននាយក ដ្ឋានសុខុមាលភាពកុមារ ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជីកុមារដែលត្រូវបានគេបោះបង់ ចោលថ្នាក់ជាតិ ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវសម្រប សម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើសំបុត្រកំណើត បញ្ចូលឈ្មោះកុមារ ទៅក្នុងបញ្ជីកុមារត្រូវធ្វើផែនការអចិន្ត្រៃយ៍ ហើយត្រូវរៀបចំបែបបទស្នើសុំតុលាការជ្រើស តាំងអ្នកអាណាព្យាបាលសម្រាប់កុមារ ។

- ចាប់ពីពេលប្រទះឃើញថា កុមារត្រូវបានគេបោះបង់រហូតដល់ពេលតុលាការជ្រើសតាំង ជនណាម្នាក់ជាអាណាព្យាបាល ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត គឺជាអាណាព្យាបាលបណ្ដោះអាសន្នរបស់កុមារ រួមទាំងក្នុងករណីដែលកុមារ កំពុងរស់នៅក្នុងមណ្ឌលដោយមានការដឹកនាំនិងពិនិត្យតាមដានរបស់ប្រធាននាយកដ្ឋាន សុខុមាលភាពកុមារ ។
- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តត្រូវរៀបចំបែបបទ ស្នើសុំតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់កុមារ លើកលែងតែកុមារដែលកំពុង រស់នៅក្នុងមណ្ឌលកុមារកំព្រា ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយក្នុងករណីនេះប្រធាននាយកដ្ឋានសុខុ មាលភាពកុមារ ត្រូវរៀបចំបែបបទស្នើសុំតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់ កុមារ ។

- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងប្រធានមណ្ឌល ត្រូវទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ ស្តីពីស្ថានភាពកុមារ និងអ្នកអាណាព្យាបាលស្របច្បាប់ និងបញ្ជូនទៅនាយកដ្ឋានសុខុមាលភាពកុមារ នូវសំណុំឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងសំណុំឯកសារកុមារ ។

## ជំពូកទី ៦

## ការថែទាំជំនួសចំពោះកុមារ

**ប្រការ ២១.-**

ករណីទុកដាក់កុមារតាមការថែទាំជំនួសទាំងអស់ត្រូវចាត់ទុកថាជា "ការថែទាំបណ្តោះអាសន្ន" លើកលែងតែការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍ ។ បន្ទាប់ពីបានខិតខំប្រឹងប្រែងធ្វើការបង្រួបបង្រួមគ្រួសារអស់លទ្ធភាព ការទុកដាក់តាមការថែទាំជំនួសបណ្តោះអាសន្នចំពោះកុមារត្រូវអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម :

ក. ការទុកដាក់ជាមួយញាតិ

ខ. ការទុកដាក់ជាមួយគ្រួសារចិញ្ចឹមនៅក្នុងសហគមន៍

គ. ការទុកដាក់តាមរបៀបថែទាំនៅក្នុងសហគមន៍ ដូចជាការថែទាំជាក្រុម និងការថែទាំតាមវត្ត (នៅក្នុងសហគមន៍ជាមួយគ្នា ហើយកុមារអាចទៅលេងឪពុកម្តាយជាទៀងទាត់)

ឃ. ការដាក់កុមារក្នុងមណ្ឌលថែទាំ ឬមណ្ឌលកុមារកំព្រា ។

**ប្រការ ២២.-**

ភារកិច្ច និងការទទួលខុសត្រូវ ក្នុងការទុកដាក់កុមារតាមរយៈការថែទាំជំនួសត្រូវអនុវត្តដូចខាងក្រោមៈ

១- នីតិបុគ្គល សមាគម អង្គការជាតិ អន្តរជាតិ និងមណ្ឌលថែទាំកុមារទាំងអស់ដែលមានកម្មវិធី និងគម្រោងផ្តល់សេវាថែទាំជំនួសចំពោះកុមារត្រូវចុះអនុស្សរណៈជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

២- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវគ្រប់គ្រងបញ្ជីបច្ចុប្បន្នភាពនៃនីតិបុគ្គល អង្គការជាតិ អន្តរជាតិ និងមណ្ឌលកុមារកំព្រាទាំងអស់ដែលផ្តល់ការថែទាំជំនួសចំពោះកុមារ ដោយកត់ត្រាឈ្មោះ អាសយដ្ឋាន និងចំនួនសរុបកុមារទាំងអស់នៅក្នុងការថែទាំជំនួសទាំងនេះទៅតាមភេទ និងអាយុ និងជំរុញការអនុវត្តឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ ។

៣- ការទុកដាក់ និងត្រួតពិនិត្យតាមដានកុមារ ដែលត្រូវទុកដាក់ជាមួយសាច់ញាតិនៅក្នុងឃុំ សង្កាត់គឺជាភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។ ចំពោះការទុកដាក់កុមារជាមួយគ្រួសារមិនមែនជាញាតិនៅក្នុងឃុំ សង្កាត់ដើមរបស់កុមារ ឬនៅឃុំសង្កាត់ផ្សេងក្នុងក្រុង ស្រុក ខណ្ឌតែមួយ គឺជាភារកិច្ចទទួលខុសត្រូវរបស់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រុង ស្រុក ខណ្ឌ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំការទុកដាក់កុមារ និងត្រួតពិនិត្យតាមដានសុខុមាលភាពកុមារដែលត្រូវបានទុកដាក់នៅក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តផ្សេងទៀត ទោះបីជាការទុកដាក់នៅក្នុងសហគមន៍ ឬក្នុងមណ្ឌលថែទាំកុមារក៏ដោយ ។

៤- មន្ត្រីដែលពាក់ព័ន្ធនឹងការទុកដាក់កុមារតាមការថែទាំជំនួសមានសិទ្ធិចូល និងត្រួតពិនិត្យមណ្ឌលថែទាំកុមារ ឬមណ្ឌលកុមារកំព្រាដោយមាន ឬមិនមានការជូនដំណឹងជាមុន ព្រមទាំងមានសិទ្ធិជួបសម្ភាសន៍ផ្ទាល់ជាមួយកុមារ និងពិនិត្យគ្រប់សំណុំឯកសារពាក់ព័ន្ធនឹងកុមារ ។

**ប្រការ ២៣.-**

ការសម្រេចក្នុងការទុកដាក់ និងការត្រួតពិនិត្យតាមដានលើការថែទាំជំនួសត្រូវអនុវត្ត ដូចខាងក្រោម៖

១- ករណីការទុកដាក់កុមារតាមរយៈការថែទាំជំនួសត្រូវបានសម្រេចថាជាការចាំបាច់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ពាក់ព័ន្ធ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវពិភាក្សាលើករណីនោះ និងសម្រេចរួមគ្នា ព្រមទាំងធ្វើឯកសារអនុញ្ញាតលើការទុកដាក់នេះ ។

២- មុននឹងទុកដាក់កុមារក្នុងការថែទាំជំនួស ត្រូវពិគ្រោះយោបល់ជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ និងកុមារជាមុនសិន (ប្រសិនបើអាច) ហើយត្រូវខិតខំប្រឹងប្រែងរក្សាកុមារនៅក្នុងសហគមន៍តែមួយជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ ឬសហគមន៍ ដែលនៅជិតបំផុត។ ត្រូវផ្តល់ព័ត៌មានដល់ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ អំពីទីកន្លែងទុកដាក់កុមារ លើកលែងតែឪពុកម្តាយ ឬអាណាព្យាបាលធ្លាប់មានប្រវត្តិរំលោភបំពាន ឬកេងប្រវ័ញ្ចលើកុមារ ដែលចាំបាច់ត្រូវរក្សាការសម្ងាត់ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៣- មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវជូនកុមារដោយផ្ទាល់ទៅកន្លែងទុកដាក់ថ្មី បន្ទាប់ពីកុមាររូបនោះបានទទួលការពិគ្រោះយោបល់រួច ហើយត្រូវពន្យល់ដល់កុមារអំពីមូលហេតុដែលកុមារត្រូវនាំទៅរស់នៅកន្លែងថ្មី អ្វីដែលកុមារអាចរំពឹងថានឹងទទួលបានពីកន្លែងថ្មី រំលឹកឡើងវិញអំពីសិទ្ធិកុមារនៅពេលនៅកន្លែងថ្មីនោះ និងប្រាប់កុមារអំពីកម្មវិធីដែលត្រូវចុះសួរសុខទុក្ខកុមារ ។ មន្ត្រីការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ឬមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ក៏ត្រូវពិគ្រោះយោបល់ជាមួយអ្នកថែទាំកុមារ អំពីកន្លែងរស់នៅថ្មី ហើយត្រូវបង្កើតផែនការផ្តល់សេវាសម្រាប់កុមារ ដោយមានការពិគ្រោះជាមុន ជាមួយកុមារ ។

៤- មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ត្រូវចុះទៅពិនិត្យតាមដាន និងសាកសួរសុខទុក្ខកុមារដែលរស់នៅក្រោមការថែទាំជំនួសឱ្យបានទៀងទាត់រៀងរាល់បីខែ

ម្តងដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ហើយត្រូវធ្វើការវាយតម្លៃជារៀងរាល់ ៦ខែម្តង លើតម្រូវការសម្រាប់សមាហរណកម្មកុមារដែលកំពុងរស់នៅក្នុងមណ្ឌល ឱ្យទៅនៅសហគមន៍វិញ។

៥- ឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៅតែមានអំណាចមេបាលើកុមារម្នាក់ ដែលបានយកទៅដាក់មណ្ឌល ដើម្បីទទួលបានការថែទាំ និង ឬការអប់រំ រហូតដល់តុលាការសម្រេចដកហូតអំណាចមេបានេះដោយសំអាងលើហេតុផលដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

៦- ក្នុងករណីមានរបាយការណ៍ អំពីការរំលោភបំពានកុមារ អំពើហិង្សា ឬការមិនយកចិត្តទុកដាក់លើកុមារដែលត្រូវទុកដាក់នៅក្នុងការថែទាំជំនួសបណ្តោះអាសន្ន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ដោយមានការត្រួតពិនិត្យពីប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ត្រូវធ្វើការស៊ើបអង្កេតភ្លាមក្នុងរយៈពេលមិនលើសពី ៤៨ (សែសិបប្រាំបី)ម៉ោង គិតចាប់ពីពេលទទួលបានរបាយការណ៍ ដោយសម្ភាសន៍កុមារ និងកំណត់តម្រូវការក្នុងការយកកុមារចេញពីការថែទាំជំនួសដោយពិគ្រោះជាមួយឪពុកម្តាយ ឬ អ្នកអាណាព្យាបាលស្របច្បាប់។ នៅពេលអាចធ្វើបាន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ឬក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវសម្ភាសន៍ជាមួយកុមាររួមគ្នាជាមួយនគរបាល និង ឬ អាជ្ញាធរឃុំ សង្កាត់ ដើម្បីកាត់បន្ថយចំនួននៃការសមាសន៍ជាមយកុមារឱ្យនៅតិចបំផុត។

៧.ប្រសិនបើការស៊ើបអង្កេតរកឃើញការរំលោភបំពានផ្លូវភេទ អំពើហិង្សាធ្ងន់ធ្ងរ ឬការគម្រាមដល់អាយុជីវិតនិងការមិនយកចិត្តទុកដាក់ចំពោះកុមារនៅក្នុងការថែទាំជំនួស មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដោយមានការត្រួតពិនិត្យពីប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ត្រូវការពារកុមារឱ្យរួចផុតពីស្ថានភាពគ្រោះថ្នាក់នោះភ្លាម តាមរយៈការបញ្ជូនជនល្មើសចេញពីកន្លែងថែទាំជំនួសបណ្តោះអាសន្ននោះ ឬក៏យកកុមារ (ប្រសិនបើចាំបាច់និងដើម្បីឧត្តមប្រយោជន៍របស់កុមារ) ទៅទុកដាក់នៅកន្លែងថែទាំមួយដែលមានកិច្ចការពារត្រឹមត្រូវនិងធានាសុវត្ថិភាពរបស់កុមារបាន។

ប្រសិនបើអាច គ្រួសាររបស់កុមារដែលត្រូវទុកដាក់នៅក្នុងការថែទាំជំនួស ត្រូវទទួលបាននូវសេវាសមស្របដែលមានគោលដៅបង្រួបបង្រួមគ្រួសារ។ ប្រសិនបើ កុមាររស់នៅឆ្ងាយពីគ្រួសាររបស់ខ្លួន ត្រូវយកកុមារទៅដាក់នៅទីកន្លែងថែទាំបណ្តោះអាសន្នដែលនៅជិតលំនៅដ្ឋានរបស់ឪពុកម្តាយកុមារ ដើម្បីងាយស្រួលអនុវត្តនីតិវិធីបង្រួបបង្រួមគ្រួសារ លើកលែងតែការបង្រួបបង្រួមគ្រួសារនោះមិនផ្តល់ប្រយោជន៍ដល់កុមារ ដោយសារប្រវត្តិនៃការរំលោភបំពាន ឬ គេងប្រវ័ញ្ចទៅលើកុមារពីអតីតកាល។

## ជំពូកទី ៧
## ការធ្វើផែនការអចិន្ត្រៃយ៍

### ប្រការ ២៤.-

កុមារដែលបានធ្វើសេវារក្សាក្នុងគ្រួសារបង្កើត និងសេវាបង្រួបបង្រួមគ្រួសារអស់លទ្ធភាពហើយ ត្រូវបញ្ជូនទៅរកសេវាការធ្វើផែនការទុកដាក់កុមារឱ្យរស់នៅជាមួយគ្រួសារជាអចិន្ត្រៃយ៍ តាមនីតិវិធីដូចខាងក្រោមនេះ :

១- មុនពេលចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍ ត្រូវមានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់ពីការប្រឹងប្រែង នៃការផ្តល់សេវារក្សាកុមារក្នុងគ្រួសារ និងសេវាបង្រួបបង្រួមគ្រួសារដែលបានធ្វើកន្លងមក ព្រមទាំងបញ្ជាក់ពីមូលហេតុ ដែលនាំឱ្យមានការសម្រេចចិត្តបញ្ជូនករណីនេះ សម្រាប់ធ្វើផែនការអចិន្ត្រៃយ៍។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ និង មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ឬមន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវសម្រេចចិត្តរួមគ្នាក្នុងការចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍នេះ។

២- ការទុកដាក់អចិន្ត្រៃយ៍ដែលអាចកំណត់ថាជោគជ័យបាន លុះត្រាតែកុមារត្រូវបានបញ្ចូលឱ្យរស់នៅក្នុងគ្រួសារមួយ ក្រោមរូបភាពជាអាណាព្យាបាលស្របច្បាប់ សុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស។

៣- រាល់ការទុកដាក់អចិន្ត្រៃយ៍ត្រូវមានដីកាសម្រេចពីតុលាការ ដកហូតអំណាចមេបាពីឪពុកម្តាយបង្កើត ឬឪពុកម្តាយកុមារបានយល់ព្រមឱ្យធ្វើផែនការអចិន្ត្រៃយ៍សម្រាប់កុមារ។ មានតែតុលាការទេ ដែលអាចសម្រេចការទុកដាក់កុមារជាអចិន្ត្រៃយ៍។

៤- ករណីដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ស្ម័គ្រចិត្តលាលែងពីអ្នកមានអំណាចមេបា ឬផ្តល់ការព្រមព្រៀងឱ្យធ្វើផែនការអចិន្ត្រៃយ៍សម្រាប់កុមារ ត្រូវផ្តល់ការពិគ្រោះយោបល់ជាមួយឪពុកម្តាយ ឬ ឪពុក ឬម្តាយ ជាមុនសិនអំពីសេវាដែលមានសម្រាប់រក្សាកុមារក្នុងគ្រួសារបាន និងលទ្ធផលចុងក្រោយ នៃការសម្រេចចិត្តរបស់ពួកគាត់។ ការពិគ្រោះយោបល់ត្រូវធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយត្រូវធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់។

## ប្រការ ២៥.-

នីតិវិធីនៃការស្វែងរកគ្រួសារអចិន្ត្រៃយសម្រាប់កុមារ ត្រូវអនុវត្តដូចខាងក្រោម:

១- ការស្វែងរកគ្រួសារថ្មីឱ្យកុមារ ត្រូវផ្តល់អាទិភាពដល់ការទុកដាក់កុមារឱ្យរស់នៅជាមួយសាច់ញាតិនៅក្នុងសហគមន៍ ឬ រាជធានី ខេត្តរបស់កុមារ។ ប្រសិនបើកុមារមានសាច់ញាតិនៅក្នុងរាជធានី ខេត្តផ្សេង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃរាជធានី ខេត្តនោះ ត្រូវសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទុកដាក់កុមារជាមួយនឹងសាច់ញាតិរបស់កុមារ។

២- ក្នុងករណីកុមារគ្មានគ្រួសារ ឬរកគ្រួសារមិនឃើញ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានី ខេត្ត ត្រូវប្រឹងប្រែងរកគ្រួសារអចិន្ត្រៃយ៍ផ្សេងទៀតនៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និង រាជធានី ខេត្តរបស់កុមារ។

៣- ក្នុងករណីមិនអាចរកគ្រួសារអចិន្ត្រៃយ៍បានសម្រាប់កុមារក្នុងរយៈពេល ៤ (បួន) ខែយ៉ាងតិច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវបញ្ជូនឈ្មោះរបស់កុមារទៅនាយកដ្ឋានសុខុមាលភាពកុមារ ដើម្បីពិចារណារកជម្រើសទុកដាក់នៅតាមបណ្តារាជធានី ខេត្ត ផ្សេងទៀត។

៤- បន្ទាប់ពីនាយកដ្ឋានសុខុមាលភាពកុមារបានពិនិត្យពិចារណា ក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍ក្នុងប្រទេសអស់រយៈពេល ៦ (ប្រាំមួយ) ខែ នៅតែរកមិនបានគ្រួសាសមស្របសម្រាប់កុមារ ត្រូវបញ្ជូន

សំណុំឯកសាររបស់កុមារទៅអាជ្ញាធរស្មុំកូនអន្តរប្រទេស ដើម្បីរកដំណោះស្រាយស្មុំកូនអន្តរប្រទេស។ រយៈពេលនេះនឹងត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយអាចធ្វើការកែប្រែឱ្យខ្លីជាងនេះ ក្នុងករណីចាំបាច់ និងសមស្រប។

## ប្រការ ២៦.-

ការទទួលខុសត្រូវក្នុងការលើកកម្ពស់នៃការទុកដាក់កុមារក្នុងប្រទេស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

១- នាយកដ្ឋានសុខុមាលភាពកុមារ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវទទួលខុសត្រូវក្នុងការលើកកម្ពស់ការទុកដាក់កុមារជាអចិន្ត្រៃយ៍នៅក្នុងប្រទេស។

២- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវធ្វើយុទ្ធនាការជាបន្តបន្ទាប់នៅតាមរាជធានី ខេត្តរៀងៗខ្លួន ដើម្បីជ្រើសរើសគ្រួសារធម៌ អាណាព្យាបាលស្របច្បាប់ និងអ្នកស្មុំកូនក្នុងប្រទេស។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវធ្វើឡើង ដោយមានការចូលរួមពីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងពីអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមិនមានកម្មវិធីធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេស។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវបណ្តុះបណ្តាលដល់គ្រួសារ និងចេញលិខិតបញ្ជាក់ជូនគ្រួសារមានបំណងយកកុមារឱ្យរស់នៅក្នុងផ្ទះរបស់ខ្លួន។

៣- នាយកដ្ឋានសុខុមាលភាពកុមារ ត្រូវកៀរគររកដៃគូអភិវឌ្ឍន៍ និងធ្វើសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំមូលនិធិ និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ក្នុងការជ្រើសរើសគ្រួសារ បណ្តុះបណ្តាលគ្រួសារ និងចេញលិខិតបញ្ជាក់ជូនគ្រួសារ។ នាយកដ្ឋានសុខុមាលភាពកុមារក៏ត្រូវដឹកនាំធ្វើយុទ្ធនាការថ្នាក់ជាតិ ដើម្បីស្វែងរកគ្រួសារ ដែលយល់ព្រមទទួលយកកុមារទៅចិញ្ចឹម និងបញ្ជូនសំណុំឯកសារគ្រួសារទាំងនោះទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត នៃលំនៅដ្ឋានរបស់កុមារ។

## ប្រការ ២៧.-

ការពង្រឹងការថែរក្សាកុមារជាអចិន្ត្រៃយ៍ជាមួយសាច់ញាតិ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១- នៅពេលសាច់ញាតិបានថែទាំកុមារអស់រយៈពេលយ៉ាងតិចប្រាំមួយខែ ហើយកុមារនោះមានការអភិវឌ្ឍល្អប្រសើរ ត្រូវចាត់ទុកថា ជាការថែទាំអចិន្ត្រៃយ៍ លើកលែងតែមានមូលហេតុដែលនាំឱ្យមានក្តីបារម្ភ។

២- ក្នុងករណីបែបនេះ ត្រូវលើកទឹកចិត្តសាច់ញាតិដែលថែទាំកុមារបានល្អនោះឱ្យធ្វើជាអាណាព្យាបាលស្របច្បាប់របស់កុមារ ឬសុំយកកុមារនោះទៅចិញ្ចឹមជាអចិន្ត្រៃយ៍ ប៉ុន្តែមិនតម្រូវ ឬបង្ខំឡើយ។

៣- ក្នុងករណីសាច់ញាតិត្រូវការជំនួយសម្រាប់ថែទាំកុមារ ត្រូវផ្តល់សេវាជំនួយទាំងនោះឱ្យគ្រួសារសាច់ញាតិនោះក្នុងនាមជាសេវារក្សាកុមារក្នុងគ្រួសារ។

## ប្រការ ២៨.-

ការសុំកូនក្នុងស្រុករួមមាន សុំកូនធម្មតា និងសុំកូនពេញលេញ។ សុំកូនក្នុងស្រុក គឺជាកិច្ចការមានអាទិភាពបំផុតសម្រាប់រកដំណោះស្រាយអចិន្ត្រៃយ៍ឱ្យកុមារ ហើយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១- សុំកូនធម្មតា និងសុំកូនពេញលេញ ត្រូវអនុវត្តទៅតាមនីតិវិធី ដែលមានចែងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណី ( ផ្នែកទី២ ពីមាត្រា១០០៧ ដល់មាត្រា១០៣៣) ។

២- រាល់ការព្រមព្រៀងចាំបាច់សម្រាប់សុំកូនក្នុងប្រទេស ត្រូវអនុវត្តទៅតាមនីតិវិធីការពារកុមារដូចគ្នានឹងសុំកូនអន្តរប្រទេស ដែលមានចែងលម្អិតនៅក្នុងច្បាប់ ស្តីពីសុំកូនអន្តរប្រទេស និងបទបញ្ញត្តិដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា។ ការពិគ្រោះយោបល់មុនពេលផ្តល់ការយល់ព្រម គឺជាលក្ខខណ្ឌចាំបាច់ក្នុងការទទួលបានការព្រមព្រៀងពីឪពុកម្តាយ ឬកុមារ។ អ្នកមានបំណងសុំកូនក្នុងស្រុក ត្រូវផ្តល់ព័ត៌មានដូចតទៅៈ ប្រវត្តិផ្ទាល់ខ្លួនអំពីស្ថិរភាពផ្លូវចិត្ត និងទំនាក់ទំនងល្អ មានលំនៅដ្ឋានសមរម្យ ហើយតំបន់រស់នៅមានសុវត្ថិភាព កុមារអាចទទួលបានការអប់រំគ្រប់គ្រាន់ និងការថែទាំសុខភាពកុមារបានជិតដល់ មានលទ្ធភាពក្នុងការផ្តល់ការគាំទ្រផ្នែកសម្ភារៈ និងផ្នែកផ្លូវចិត្តដល់កុមារ មានបំណងពិតប្រាកដក្នុងការចិញ្ចឹមកូនសុំនោះឱ្យដូចគ្នាទៅនឹងកូនបង្កើតរបស់ខ្លួន និងអារម្មណ៍របស់កុមារផ្សេងទៀតដែលរស់នៅក្នុងគ្រួសារនោះ ។

៣- អ្នកសុំកូនត្រូវតម្រូវឱ្យផ្តល់នូវឯកសារមួយចំនួន និងត្រូវសម្ភាសជាចាំបាច់ ដើម្បីធ្វើការសម្រេចចិត្ត ហើយត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់អះអាងថា អ្នកសុំនោះនឹងចាត់ទុកកូនសុំឱ្យដូចកូនបង្កើតរបស់ខ្លួន និងផ្តល់នូវការឧបត្ថម្ភគាំទ្រ សេចក្តីស្រឡាញ់ ការអប់រំ និងកេរមតិក រួមទាំងកុមារទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតរបស់ខ្លួន។

មន្ត្រី នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវធ្វើការវិនិច្ឆ័យឱ្យបានហ្មត់ចត់ក្នុងការធ្វើរបាយការណ៍ អំពីលក្ខណៈសម្បត្តិរបស់គ្រួសារដែលសុំកូន បន្ទាប់មកត្រូវរៀបចំកិច្ចប្រជុំជាមួយការិយាល័យដែលមានការពាក់ព័ន្ធរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត (បើមាន) មុនពេលគ្រួសារទទួលការយល់ព្រមនៅទីបញ្ចប់។ បន្ទាប់ពីទទួលបានការយល់ព្រមអ្នកសុំកូនត្រូវបំពេញទម្រង់ដើម្បីស្នើសុំសេចក្តីសម្រេចពីតុលាការ។ ការសុំកូនក្នុងប្រទេស ត្រូវមានរយៈពេលសាកល្បងចំនួន៦( ប្រាំមួយ)ខែសិន មុននឹងតុលាការសម្រេចចេញសាលក្រមសម្រេចជាស្ថាពរ។ ក្នុងអំឡុងពេលនៃការសាកល្បងនេះ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត នៅតែបន្តធ្វើជាអ្នកអាណាព្យាបាលរបស់កុមារ លើកលែងតែកុមារនោះរស់នៅក្នុងមណ្ឌលដែលគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលប្រធាននាយកដ្ឋានសុខុមាលភាពកុមារ គឺជាអ្នកអាណាព្យាបាលរបស់កុមារ និងត្រូវផ្តល់នូវសេវានានា ដើម្បីបង្កើនឱកាសឱ្យរយៈពេលអន្តរកាលនេះ

មានជោគជ័យឈានទៅរកសុំកូនអចិន្ត្រៃយ៍។ ប្រសិនបើកុមារ និងគ្រួសារមានការរស់នៅចុះសម្រុងគ្នាល្អ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវជួយគ្រួសារ ដើម្បីទទួលបានការសម្រេចជាស្ថាពរចុងក្រោយទៅលើការសុំកូន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរកើតឡើង ហើយការសុំកូនមានដំណើរការមិនល្អ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍ផ្សេងទៀតសម្រាប់កុមារ ។

**ប្រការ ២៩.-**

នីតិវិធីសម្រាប់ការថែទាំកុមារជាអចិន្ត្រៃយ៍ដោយគ្រួសារធម៌ ដែលមិនជាប់សាច់ញាតិជាមួយកុមារ ត្រូវអនុវត្តដូចខាងក្រោម :

១- កុមារដែលត្រូវទុកដាក់ឱ្យទទួលការចិញ្ចឹមថែទាំពីគ្រួសារធម៌មួយដែលមិនជាប់សាច់ញាតិ អស់រយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងតិច ត្រូវចាត់ទុកជាមុខសញ្ញាសម្រាប់ទុកដាក់ជាលក្ខណៈអាណាព្យាបាលអចិន្ត្រៃយ៍ជាមួយគ្រួសារដែលបានថែទាំកុមារនោះ ។

២- ករណីកុមារនិងគ្រួសារមានលក្ខណៈសមស្របដូចគ្នា ត្រូវលើកទឹកចិត្ត និងផ្តល់ជំនួយខាងផ្លូវច្បាប់ដល់គ្រួសារនោះ ដើម្បីឈានទៅទទួលបានភាពជាអាណាព្យាបាលស្របច្បាប់របស់អនីតិជន ឬឈានដល់ការសុំកុមារនោះជាកូន បើពុំដូច្នេះទេ ត្រូវបន្តធ្វើការត្រួតពិនិត្យ តាមដានការទុកដាក់កុមារនេះទៅតាមការចាំបាច់ និងត្រូវខិតខំស្វែងរកគ្រួសារអចិន្ត្រៃយ៍ឱ្យកុមារជាបន្តទៅទៀត ។

**ប្រការ ៣០.-**

សម្រាប់កុមារដែលមានអាយុឈានដល់ ១៥ ឆ្នាំ នៅក្នុងមណ្ឌល នាយកដ្ឋានសុខុមាលភាពកុមារ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវសហការជាមួយប្រធានមណ្ឌល និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា ក្នុងការផ្តល់នូវសេវានានា ដូចជាបំណិនជីវិត ជំនាញវិជ្ជាជីវៈ ផែនការបន្តការសិក្សា និងជំនាញគ្រប់គ្រងធនធានជាដើម ដើម្បីត្រៀមលក្ខណៈកុមារសម្រាប់ការឈានចូលភាពពេញវ័យ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**ប្រការ ៣១.-**

បទប្បញ្ញត្តិទាក់ទងនឹងការត្រួតពិនិត្យ ការទុកដាក់ និងការធ្វើផែនការសម្រាប់រកគ្រួសារអចិន្ត្រៃយ៍ឱ្យកុមារ នឹងមានចែងលំអិតនៅក្នុងសៀវភៅគោលការណ៍ណែនាំក្នុងការអនុវត្ត ។

**ប្រការ ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣៣.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃក្រុមប្រឹក្សារាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មន្ត្រីឃុំ សង្កាត់ទទួលបន្ទុកសុខុមាលភាពកុមារ ត្រូវមានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ ***សម្តេចនាយករដ្ឋមន្ត្រី***
- ខុទ្ទកាល័យលោកជំទាវ ***ម៉ែន សំអន*** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ
- ដូចប្រការ ៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ